# អារម្ភកថា

ក្នុងជម្រៅនៃដួងចិត្តមនុស្សស្រី តែងបង្កប់នូវកម្លាំងដ៏អស្ចារ្យមួយ ដែលពិបាកនឹងស្មានដល់។ ភាពរឹងមាំនោះ ពេលខ្លះត្រូវបានលាក់បាំងក្រោមស្រទាប់នៃភាពឈឺចាប់ ទុក្ខសោក និងការអត់ទ្រាំរាប់មិនអស់។ រឿង "កែវភ្នែកនាង" នេះគឺជាបំណែកមួយនៃជីវិតពិត ដែលបានឆ្លុះបញ្ចាំងពីទិដ្ឋភាពដ៏លំបាករបស់គ្រួសារមួយ ដែលត្រូវប្រឈមមុខនឹងភាពព្រងើយកន្តើយ ការមិនឱ្យតម្លៃ និងរហូតឈានទៅដល់ការបោះបង់គ្រួសារចោល។

តាមរយៈរឿងរ៉ាវរបស់ជាតា ស្ត្រីដែលបានលះបង់គ្រប់យ៉ាងដើម្បីគ្រួសារ និងដើម្បីកូនប្រុសជាទីស្រលាញ់ តែត្រូវទទួលបានមកវិញនូវការខកចិត្តនិងទឹកភ្នែក យើងនឹងបានឃើញនូវការតស៊ូរបស់នាង កែវភ្នែករបស់នាងបង្ហាញពីការឈឺចាប់របស់នាងយ៉ាងច្បាស់។ តាំងពីដំបូងឡើយពោរពេញដោយការឈឺចាប់រាប់មិនអស់ យំជាច្រើនដង ប៉ុន្តែនៅទីបំផុត នារីទន់ខ្សោយម្នាក់នេះនឹងបង្ហាញភាពក្លាហាន និងការសម្រេចចិត្តយ៉ាងមុតមាំ រួចបង្កើតក្តីសង្ឃឹមសម្រាប់ជីវិតថ្មីមួយ។

រឿងនេះនឹងនាំអ្នកទៅកាន់ដំណាក់កាលផ្សេងៗនៃជីវិតរបស់ជាតា ចាប់តាំងពីការចាប់ផ្តើមនៃភាពឈឺចាប់ រហូតដល់ការសម្រេចចិត្តដើរចេញពីផ្លូវដែលគ្មានអនាគត ហើយចុងក្រោយរកឃើញពន្លឺដ៏ភ្លឺស្វាងនៃជីវិតថ្មី។ វាជាសក្ខីភាពមួយ

នៃកម្លាំងចិត្តរបស់ម្តាយ កម្លាំងចិត្តរបស់មនុស្សស្រី និងការស្វែងរកសុភមង្គលពិតប្រាកដដោយខ្លួនឯង។

សូមចូលរួមអានរឿង "កែវភ្នែកនាង" ដើម្បីស្វែងយល់ពីការលះបង់ ភាពរឹងមាំ និងដំណើរដ៏វែងឆ្ងាយនៃការជាសះស្បើយពីរបួសក្នុងចិត្ត ទីបំផុតបាននាំទៅរកសេរីភាពនិងពន្លឺនៃក្តីសង្ឃឹមពិតប្រាកដ។

# មាតិកា

ភាគទី ១៖ សំណើមនៃភាពឈឺចាប់

ភាគទី ២៖ វង្វេងសម្លាជ

ភាគទី ៣៖ ផ្លូវបំបែក

ភាគទី ៤៖ ការចាប់ផ្តើមជីវិតថ្មី

ភាគទី ៥៖ ក្តីសង្ឃឹមនិងអនាគត

# សំណើមនៃភាពឈឺចាប់

ដើងមេឃចាប់ផ្ដើមប្រែជាស្រាលបន្តិចម្ដងៗ ទៅជាពណ៌ទឹកប៊ិចលាយក្រហមឆ្អៅ នៅឯជ្រុងបង្អួចនៃបន្ទប់គេងដ៏ស្ងប់ស្ងាត់មួយក្នុងផ្ទះវីឡាកណ្ដាលក្រុងភ្នំពេញ។ សម្លេងសត្វចាបចាប់ផ្ដើមរំពងឡើងពីដើមឈើខាងក្រៅ ហាក់ដូចជាប្រកាសពីការមកដល់នៃថ្ងៃថ្មីដែលពោរពេញទៅដោយសកម្មភាពនិងក្ដីសង្ឃឹម ប៉ុន្តែសម្រាប់ជាតា ថ្ងៃថ្មីនេះមិនបាននាំមកនូវពន្លឺនៃក្ដីសង្ឃឹមអ្វីឡើយ។ រៀងរាល់ព្រឹក នាងតែងតែអង្គុយទ្រឹងនៅលើកៅអីក្បែរបង្អួចនេះ ភ្នែកទាំងគូសម្លឹងទៅភាពទទេរស្អាតនៃផ្ទៃមេឃខាងក្រៅ ទាំងបេះដូងលោតខុសចង្វាក់រង់ចាំមនុស្សម្នាក់ដែលនាងមិនដឹងថានឹងមកដល់ពេលណា ដំណក់ទឹកភ្នែកមួយតំណក់បានហូររំអិលចុះមកលើថ្ពាល់របស់នាង ឆ្លុះបញ្ចាំងពន្លឺថ្ងៃដំបូងដែលចាំងចូលមកក្នុងបន្ទប់ បង្កើតបានជាពន្លឺភ្លឺបភ្លែតដែលមើលទៅដូចជាត្បូងពេជ្រថ្លា។ វាជាទិដ្ឋភាពដ៏ស្រស់ស្អាត ប៉ុន្តែបង្កប់ដោយការឈឺចាប់យ៉ាងខ្លាំង។

ឥឡូវនេះគឺម៉ោង៥ព្រឹកបាត់ទៅហើយ ប៉ុន្តែតារាជាប្ដីនៅតែមិនទាន់ត្រឡប់មកផ្ទះវិញនោះទេ នេះមិនមែនជាលើកទីមួយទេ ហើយនាងក៏ដឹងថាក៏មិនមែនជាលើកចុងក្រោយដែរ។ ជាតារៀបការជាមួយតារាបានប្រាំពីរឆ្នាំមកហើយ ហើយក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ជីវិតរបស់នាងបានប្រែប្រួលទាំងស្រុង។ រាល់យប់គឺបែបនេះឯង តារាតែងចំណាយពេលជាមួយមិត្តភ័ក្តិនៅក្រៅផ្ទះផឹកស៊ីរហូតដល់ម៉ោង១ ម៉ោង២ ឬពេលខ្លះរហូតដល់ជិតភ្លឺទើបត្រឡប់មកវិញ។ រាល់

ពេលដែលគាត់ចូលមកដល់ផ្ទះ ក្លិនស្រានិងបារីបានសាយភាយពេញផ្ទះទាំងមូល ហាក់ដូចជាប្រកាសពីវត្តមានរបស់គាត់ដែលជាបន្ទុកមួយសម្រាប់ចិត្តជាតា។ គាត់ចូលមកគេងដោយមិននិយាយអ្វីមួយម៉ាត់ ពេលខ្លះក៏មានសំឡេងរអ៊ូរទាំខ្លះៗដែរ ជាតាដឹងថាគាត់មិនបានឱ្យតម្លៃនាងជាប្រពន្ធសោះឡើយ ហើយអ្វីដែលធ្វើឱ្យនាងឈឺចាប់បំផុតនោះគឺគ្រួសារខាងប្ដីក៏មិនបានយល់ចិត្តនាងដែរ។

ជាតានៅចាំបានយ៉ាងច្បាស់ពីថ្ងៃដែលនាងបានរៀបការជាមួយតារា នាងស្រលាញ់គាត់អស់ពីចិត្ត ហើយសង្ឃឹមថានឹងមានជីវិតគ្រួសារដ៏កក់ក្ដៅមួយដែលពោរពេញទៅដោយក្ដីស្រលាញ់និងការយល់ចិត្តគ្នា។ តារាធ្លាប់ជាបុរសដែលមានមន្តស្នេហ៍ ចេះយល់ចិត្ត ចេះយកអាសារ ហើយតែងតែផ្តល់ភាពកក់ក្តៅឱ្យនាង។ រាល់ពេលដែលជាតាមានបញ្ហា ឬពិបាកចិត្ត គាត់តែងតែនៅក្បែរលួងលោមនាង គាត់តែងតែនិយាយពាក្យផ្អែមល្ហែមជាច្រើនដូចជា៖

**"អូនជាមនុស្សស្រីតែម្នាក់គត់ក្នុងជីវិតបង" "បងនឹងមើលថែអូនអស់មួយជីវិត"**

ពាក្យទាំងនោះនៅតែលឺរងំក្នុងត្រចៀកជាតារហូតដល់សព្វថ្ងៃ ប៉ុន្តែវាបានក្លាយទៅជាស្នាមរបួសដែលមិនអាចជាសះស្បើយ។

ក្រោយពីរៀបការបានប៉ុន្មានឆ្នាំ និងក្រោយពីរតនាកើតមក អ្វីៗក៏ចាប់ផ្តើមផ្លាស់ប្តូរ តារាកាន់តែឃ្លាតឆ្ងាយពីនាង កាន់តែមិនអើពើនឹងនាង។ គាត់ហាក់ដូចជារក

ឃើញភាពសប្បាយរីករាយនៅក្រៅផ្ទះច្រើនជាងនៅក្នុងផ្ទះ មិត្តភ័ក្តិបានក្លាយជាមនុស្សសំខាន់ជាងប្រពន្ធកូន ពេលខ្លះជាតាក៏ព្យាយាមទៅហៅគាត់ត្រឡប់មកផ្ទះវិញដែរ។ នាងនៅចាំបានម្តង នាងបានទៅដល់ក្លឹបកម្សាន្តមួយកន្លែងដែលតារានិងមិត្តភ័ក្តិរបស់គាត់កំពុងជួបជុំគ្នា នាងទៅដល់ទាំងចិត្តសង្ឃឹមថាគាត់នឹងយល់ពីការបារម្ភរបស់នាង៖

**"បង! ត្រឡប់ទៅផ្ទះវិញទៅ វាយប់ជ្រៅណាស់ហើយ។"** ជាតានិយាយទាំងសំឡេងតិចៗ តារាបានងាកមកមើលនាងទាំងទឹកមុខមិនពេញចិត្ត ៖

**"នាងមកធ្វើអីនៅទីនេះ? ត្រឡប់ទៅផ្ទះវិញទៅ! នេះមិនមែនជាកន្លែងសម្រាប់នាងទេ។"**

គាត់និយាយទាំងទឹកមុខមាំ មិត្តភ័ក្តិរបស់គាត់បានសម្លឹងមកនាងទាំងកែវភ្នែកចំអក ជាតាមានអារម្មណ៍ថាខ្លួនឯងដូចជាមនុស្សឆ្កួតដែលបានទៅទីនោះ។ នាងបានត្រឡប់មកផ្ទះវិញទាំងទឹកភ្នែក ហើយចាប់ពីពេលនោះមក នាងលែងហ៊ានទៅតាមគាត់ទៀតហើយ។

ជាតាជកដង្ហើមធំ រូបភាពកូនប្រុសតូចរបស់នាងឈ្មោះរតនាបានលេចឡើងក្នុងគំនិតនាង។ រតនាជាបេះដូងរបស់នាង ជាកម្លាំងចិត្តរបស់នាង។ ក្នុងអាយុប្រាំឆ្នាំ រតនាជាក្មេងប្រុសដ៏ឆ្លាតវៃ និងគួរឱ្យស្រលាញ់ នាងសុខចិត្តទ្រាំនឹងការឈឺ

ចាប់ទាំងអស់នេះដើម្បីកូន មិនចង់ឱ្យរតនាក្លាយជាក្មេងកំព្រាឪពុកម្តាយបែកគ្នាឡើយ។ រាល់យប់មុននឹងចូលគេង រតនាតែងតែសួររកឪពុករបស់គេ៖

**"ម៉ាក់! ប៉ាទៅណា? ហេតុអីប៉ាអត់មកគេងជាមួយយើង?"**

សំណួរដ៏សាមញ្ញរបស់កូនប្រុសបានចាក់ទម្លុះបេះដូងជាតារាប់មិនអស់ នាងតែងតែឆ្លើយដោយពាក្យកុហកកូន៖

**"ប៉ារវល់ការងារកូនអើយ តិចទៀតគាត់មកហើយ" ឬ "ប៉ាទៅរកលុយឱ្យរតនារៀនសូត្រអីចឹងទៅ"។**

អ្វីដែលធ្វើឱ្យនាងពិបាកចិត្តជាងនេះទៅទៀតនោះគឺគ្រួសារខាងប្តី ម្តាយក្មេករបស់នាងតែងតែនិយាយបង្អាប់នាងថាជាប្រពន្ធមិនល្អ៖

**"ឯងជាប្រពន្ធ ត្រូវចេះឃាត់ប្តីឱ្យនៅផ្ទះ បើប្តីទៅដើរលេងច្រើន មកពីឯងមិនចេះរៀបចំផ្ទះ មិនចេះនិយាយពិរោះ"។**

សាច់ថ្លៃរបស់នាងក៏មិនខុសគ្នាដែរពួកគេតែងតែនិយាយដើមនាងនៅពីក្រោយខ្នង៖

**"ជាតានេះវាអត់ចេះឃាត់ប្ដីសោះ" "មើលទៅដូចអត់មានប្រពន្ធសោះ"**

ពាក្យទាំងនេះបានលឺដល់ត្រចៀកជាតាជារឿយៗ ពេលខ្លះក៏លឺផ្ទាល់តែម្ដងដែរ ពួកគេមិនយល់ថាជាតាបានព្យាយាមប៉ុណ្ណានោះទេ ពួកគេមិនយល់ពីការឈឺចាប់ដែលនាងកំពុងស៊ូទ្រាំនោះទេ។ ពួកគេមើលឃើញតែកំហុសរបស់នាង តែមិនដែលមើលឃើញពីទង្វើរបស់តារាដែលជាកូនប្រុសរបស់ពួកគេឡើយ។

ជាតាជាមនុស្សស្រីរឹងមាំ មិនចង់បង្ហាញភាពទន់ខ្សោយឱ្យនរណាឃើញឡើយ នាងយំម្នាក់ឯងរាល់យប់ពេលដែលរតនាគេងលក់ នាងយកខ្នើយមកបិទមាត់ដើម្បីកុំឱ្យសំឡេងយំរបស់នាងលឺដល់កូន។

ទឹកភ្នែកជាមិត្តស្មោះត្រង់របស់នាងពេលយប់ វាជាមធ្យោបាយតែមួយគត់ដែលនាងអាចបញ្ចេញនូវអារម្មណ៍ឈឺចាប់ដែលបង្កប់ក្នុងចិត្តបាន នាងតែងបន់ស្រន់សុំឱ្យតារាផ្លាស់ប្ដូរ ឱ្យគាត់ត្រឡប់មកជាមនុស្សដើមវិញ។ នាងនៅតែសង្ឃឹមថាភាពកក់ក្ដៅដែលធ្លាប់មានក្នុងគ្រួសារមួយនេះនឹងត្រឡប់មកវិញថ្ងៃណាមួយ។

ព្រឹកនោះ តារាបានត្រឡប់មកវិញនៅម៉ោង៦ព្រឹក ជាមួយនឹងក្លិនស្រាដែលសាយភាយចេញពីខ្លួនគាត់ គាត់ចូលមកបន្ទប់គេងទាំងមិនបានសូម្បីតែងាកមើលទៅជាតាដែលកំពុងអង្គុយនៅក្បែរបង្អួច គាត់ដោះអាវចេញហើយចូលទៅក្នុងបន្ទប់ទឹក ជាតាបានលឺសំឡេងទឹកហូរពីផ្កាឈូកយ៉ាងច្បាស់ បន្ទាប់ពីងូតទឹករួច គាត់ក៏ចូលមកគេងភ្លាមដោយមិនបាននិយាយអ្វីមួយម៉ាត់សោះឡើយ។ ជាតាក្រឡេកមើលទៅគាត់ ឃើញទឹកមុខគាត់ដែលមើលទៅហត់នឿយ ហើយបិទភ្នែកជិត នាងបានត្រឹមតែដកដង្ហើមធំ ហើយរៀបចំខ្លួនទៅធ្វើការ។

នៅពេលដែលជាតាកំពុងរៀបចំអាហារពេលព្រឹកឱ្យរតនា រតនាបានរត់មកអោបជើងនាង៖

**"ម៉ាក់! ប៉ានៅឯណា? ខ្ញុំចង់លេងជាមួយប៉ា!" កែវភ្នែកដ៏ស្លូតបូតរបស់រតនាបានសម្លឹងមកនាង ជាតាបានឱនចុះហើយថើបថ្ពាសកូនប្រុសរបស់នាង "ប៉ាគេងហើយកូនអើយ គាត់ហត់ណាស់។ រតនាទៅញ៉ាំបាយទៅ តិចទៀតម៉ាក់ជូនទៅសាលា។"**

រតនាបានងក់ក្បាលហើយរត់ទៅតុអាហារ ជាតាមើលទៅកូនប្រុសរបស់នាងដែលកំពុងញ៉ាំបាយយ៉ាងឆ្ងាញ់ នាងដឹងថាទោះបីជានាងត្រូវរងទុក្ខប៉ុណ្ណាក៏ដោយ ក៏នាងមិនអាចបោះបង់ការស្រលាញ់របស់ម្តាយចំពោះកូនបានឡើយ។ រតនាជាហេតុផលតែមួយគត់ដែលនាងនៅតែទ្រាំរស់នៅក្នុងស្ថានភាពបែបនេះ



នាងមិនចង់ឱ្យរតនាបាត់បង់ភាពកក់ក្តៅពីឪពុកទោះជាឪពុកនោះមិនសូវយកចិត្តទុកដាក់ក៏ដោយ នាងសង្ឃឹមថាថ្ងៃណាមួយ តារានឹងភ្ញាក់ខ្លួន ហើយត្រឡប់មកបំពេញតួនាទីជាឪពុកគេវិញ កែវភ្នែករបស់នាងបានសម្លឹងមើលទៅរតនាដោយក្តីស្រលាញ់ដ៏ជ្រាលជ្រៅនិងភាពឈឺចាប់ដែលបង្កប់ទុកក្នុងចិត្ត។

## ទឹកភ្នែកដែលហូរ! ហូរម្តងនេះឱ្យអស់កម្ម។

# វេទសម្ពាធ

មួយរយៈក្រោយមក ស្ថានការណ៍ក្នុងគ្រួសាររបស់ដាតាមិនបានប្រសើរឡើងវិញនោះទេ ផ្ទុយទៅវិញវាកាន់តែអាក្រក់ទៅៗ រាល់ថ្ងៃដាតាមានអារម្មណ៍ថាដូចជាកំពុងដើរនៅលើផ្លូវដែលពោរពេញដោយបន្លា គ្រប់ជំហានសុទ្ធតែបង្កប់ដោយការឈឺចាប់និងការខកចិត្តរាប់មិនអស់។ តារាជាប្ដីហាក់ដូចជាលែងខ្វល់ពីអ្វីទាំងអស់ដែលទាក់ទងនឹងផ្ទះសម្បែងនិងគ្រួសារដែលគាត់ធ្លាប់សាង គាត់លែងត្រឡប់មកផ្ទះត្រឹមម៉ោង១ ឬម៉ោង២យប់ទៀតហើយ តែពេលខ្លះគឺម៉ោង៣ ម៉ោង៤ ឬសូម្បីតែមិនត្រឡប់មកផ្ទះមួយយប់ក៏មានដែរ ដោយមិនបានខ្វល់ថាមានប្រពន្ធកូនកំពុងរង់ចាំនោះទេ រាល់ពេលដែលដាតាព្យាយាមនិយាយជាមួយគាត់ គាត់តែងតែគេចវេះ ឬនិយាយដោយសំឡេងរឹងត្អឹងថា៖

**"រឿងរបស់បង អូនមិនចាំបាច់ចេះដឹងទេ" ឬ "នាងគិតតែពីរឿងរបស់អូនទៅបានហើយ"**

ដោយហាក់ដូចជាប្រពន្ធកូនមិនមែនជាផ្នែកមួយនៃជីវិតរបស់គាត់ទៀតទេ។

មិនត្រឹមតែការមិនអើពើនិងការមិនផ្ដល់តម្លៃប៉ុណ្ណោះទេ តារាក៏ចាប់ពិបាករឿងលុយកាក់ផងដែរ។ គាត់ធ្លាប់ជាអ្នកដែលផ្ដល់ប្រាក់កាសគ្រប់គ្រាន់សម្រាប់គ្រួសារដោយមិនឱ្យដាតាបារម្ភអ្វីឡើយ ប៉ុន្តែឥឡូវនេះគាត់តែងតែនិយាយថាគ្មានលុយ ហើយពេលខ្លះក៏មិនទាំងផ្ដល់លុយឱ្យដាតាទុកប្រើប្រាស់ក្នុងផ្ទះដែរ។ លុយកាក់ដែលគាត់រកបានពីមុខរបរលក់គ្រឿងបន្លាស់រថយន្ត គឺត្រូវបានចំណាយទៅលើការផឹកស៊ី ការលេងល្បែង និងការកម្សាន្តជាមួយមិត្តភ័ក្តិអស់។

ជាតាត្រូវយកប្រាក់ខែដែលខ្លួនរកបានពីការងារជាបុគ្គលិករដ្ឋបាលនៅក្រុមហ៊ុនឯកជនមួយមកផ្គត់ផ្គង់ការចំណាយក្នុងផ្ទះស្ទើរតែទាំងស្រុង រួមទាំងថ្លៃម្ហូបអាហារ ថ្លៃទឹកភ្លើង ថ្លៃសាលារបស់តេនា និងការចំណាយផ្សេងៗទៀត។ រាល់ពេលដែលវិក្កយបត្រមកដល់ ជាតាត្រូវតែគិតយ៉ាងលំបាកពីវិធីដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ពេលខ្លះនាងក៏ត្រូវខ្ចីលុយពីម្តាយរបស់នាងដែរ ដែលធ្វើឱ្យនាងមានអារម្មណ៍មិនល្អទាល់តែសោះ និងរអៀសចិត្តជាខ្លាំង។ ភាពតានតឹងផ្នែកហិរញ្ញវត្ថុបានបន្ថែមបន្ទុកយ៉ាងធ្ងន់ធ្ងរលើស្មារបស់នាង ដែលជាអម្រែកមួយស្ទើរតែទ្រាំលែងបានទៅហើយ។

មិនតែប៉ុណ្ណោះ ការមិនផ្តល់តម្លៃពីគ្រួសារខាងប្តីក៏កាន់តែខ្លាំងឡើងៗ រៀងរាល់ចុងសប្តាហ៍ ជាតាតែងតែនាំតេនាទៅលេងផ្ទះម្តាយក្មេក ដែលជាផ្ទះធំមួយមានសមាជិកច្រើន ប៉ុន្តែវត្តមានរបស់នាងហាក់ដូចជាមិនត្រូវបានស្វាគមន៍សោះឡើយ។ ម្តាយក្មេករបស់នាងតែងតែរករឿងបន្ទោសនាងនៅចំពោះមុខបងប្អូនថ្លៃ និងសាច់ញាតិដទៃ៖

**"ជាតា! ម្តេចក៏ឯងមិនចេះធ្វើម្ហូបឆ្ងាញ់ៗឱ្យប្តីស៊ីផង? បានជាគាត់មិនចង់នៅផ្ទះ ឯងជាប្រពន្ធ ត្រូវចេះគ្រប់គ្រងប្តីរបស់ឯង"**

**ឬ "ឯងគួរតែស្លៀកពាក់ឱ្យស្អាតៗ ហើយចេះលេងសើចជាមួយវាខ្លះផង ក្រែងលោវាបានកម្លាំងចិត្តពីឯង"**

ជាតាតែងតែព្យាយាមពន្យល់ថានាងបានព្យាយាមអស់ពីសមត្ថភាពហើយ ប៉ុន្តែម្តាយក្មេករបស់នាងមិនដែលស្តាប់ឡើយ គាត់តែងតែមើលឃើញតែកំហុស

របស់នាង តែមិនដែលមើលឃើញពីទង្វើរបស់តាវាដែលជាកូនប្រុសរបស់គាត់ឡើយ។

បងប្អូនថ្លៃរបស់នាងក៏តែងតែលួចនិយាយដើមនាងនៅពីក្រោយខ្នងដែរ ហើយពេលខ្លះក៏និយាយដោយមិនលាក់លៀមដែរ៖

**"ជាតានេះវាអត់មានមន្តស្នេហ៍ជាប្រពន្ធសោះ បានជាបងតាវាទៅរកសប្បាយនៅខាងក្រៅ"។**

**"មុខស្លេកៗដូចខ្មោចអ៊ីចឹង តើអ្នកណាទៅចង់នៅជិត"។**

ពាក្យទាំងនេះបានលឺដល់ត្រចៀកជាតាជាច្រើនដងរហូតដល់នាងមានអារម្មណ៍ថាខ្លួនឯងដូចជាមនុស្សគ្មានតម្លៃ គ្មានអ្នកណាយល់ចិត្តទាល់តែសោះ។ នាងមានអារម្មណ៍ឯកាខ្លាំងណាស់ មិត្តភ័ក្តិរបស់នាងក៏ចាប់ផ្តើមឃ្លាតឆ្ងាយពីនាងបន្តិចម្តងៗ ដោយសារតែនាងលែងមានពេលវេលាសម្រាប់ពួកគេ ហើយនាងក៏មិនចង់រៀបរាប់ពីបញ្ហារបស់នាងឱ្យនរណាស្តាប់ដែរ នាងរឹតតែឃុំខ្លួនឯងក្នុងភាពឈឺចាប់និងទុក្ខសោក។

រតនាដែលឥឡូវនេះមានអាយុប្រាំឆ្នាំហើយ ក៏ចាប់ផ្តើមកត់សម្គាល់ពីភាពតានតឹងរវាងឪពុកម្តាយរបស់គេដែរ គេលែងសួររកប៉ាញឹកញាប់ដូចមុនទៀតហើយ។ តែពេលខ្លះគេបែរជាសួរសំណួរដែលធ្វើឱ្យជាតារឹតតែពិបាកឆ្លើយ និង

ឈឺចាប់៖

**"ម៉ាក់! ហេតុអីប៉ាអត់ញ៉ាំបាយជាមួយយើង? ប៉ាអត់ស្រលាញ់រតនាទេមែន?"**

សំណួរទាំងនេះបានចាក់ដោតបេះដូងជាតារាល់ថ្ងៃ។ នាងដឹងថារតនាកំពុងតែរងផលប៉ះពាល់ពីបញ្ហាគ្រួសារនេះ ប៉ុន្តែនាងមិនដឹងថាត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយវាឡើយ ថ្ងៃខ្លះ រតនាក៏បានឃើញម្ដាយរបស់គេយំដោយលួចលាក់ដែរ ទោះជាជាតាព្យាយាមលាក់បាំងយ៉ាងណាក៏ដោយ ក្មេងតូចនោះក៏ចាប់ផ្ដើមមានទឹកមុខស្រងូតស្រងាត់មិនសូវរីករាយដូចកាលពីមុនឡើយ។

ជាតាបានព្យាយាមនិយាយជាមួយតារាជាច្រើនលើកច្រើនសារដើម្បីដោះស្រាយបញ្ហាទាំងនេះ នាងបានប្រាប់គាត់ថានាងពិបាកចិត្តប៉ុណ្ណា នាងបានប្រាប់គាត់ថារតនាត្រូវការវត្តមានរបស់ឪពុកប៉ុណ្ណា។ នាងបានព្យាយាមពន្យល់គាត់ថាការបាត់បង់តម្លៃពីគ្រួសាររបស់គាត់ធ្វើឱ្យនាងឈឺចាប់យ៉ាងណា នាងថែមទាំងបានស្នើឱ្យគាត់ទៅជួបអ្នកប្រឹក្សាយោបល់គ្រួសារទៀតផង ប៉ុន្តែរាល់ការព្យាយាមរបស់នាងត្រូវបានតារាបដិសេធឬបណ្ដេញចេញដោយការព្រងើយកន្តើយឬក៏ជះកំហឹងដាក់នាងទៅវិញ៖

**"អូនគិតតែពីខ្លួនឯង! មិនដែលយល់ពីការងាររបស់បងទេ! កុំរំខានបងទៀត!"**

គាត់តែងតែលើកហេតុផលបែបនេះមក។ ការនិយាយគ្នាភាគច្រើនបានបញ្ចប់ដោយការឈ្លោះប្រកែកគ្នាឬភាពស្ងៀមស្ងាត់ដ៏គួរឱ្យភ័យខ្លាចដែលធ្វើឱ្យបរិយាកាសក្នុងផ្ទះកាន់តែតានតឹង។

មានថ្ងៃមួយជាតានៅចាំបានយ៉ាងច្បាស់ វាជាថ្ងៃបុណ្យភ្ជុំបិណ្ឌ។ ជាតាបានរៀបចំម្ហូបអាហារជាច្រើនមុខដើម្បីយកទៅវត្តជាមួយតារានិងរតនា នាងសង្ឃឹមថាការទៅវត្តជាមួយគ្នានឹងអាចនាំមកនូវភាពកក់ក្តៅខ្លះៗក្នុងគ្រួសារ។ នាងបានដាស់តារាតាំងពីព្រលឹម ប៉ុន្តែគាត់បាននិយាយថា "អូនទៅមុនទៅ បងអត់ទាន់បានគេងគ្រប់ទេ" ជាតាបាននាំរតនាទៅវត្តទាំងការខកចិត្ត។ នៅពេលដែលពួកគេត្រឡប់មកផ្ទះវិញ តារានៅតែគេងលក់នៅឡើយ។ រតនាបានរត់ទៅដាស់ឪពុករបស់គេទាំងទឹកមុខរីករាយ៖

**"ប៉ា! យើងទៅវត្តហើយ! ប៉ាអត់បានទៅទេ!" តារាបានងាកខ្លួនទាំងហត់នឿយហើយនិយាយថា "អូ... ប៉ាភ្លេចបាត់ទៅហើយ" ជាតាបានឃើញពីភាពខកចិត្តក្នុងកែវភ្នែករបស់រតនា។**

នៅពេលល្ងាចថ្ងៃដដែលនោះ ម្តាយក្មេកនិងបងប្អូនថ្លៃបានមកលេងផ្ទះ ពួកគេបានឃើញតារាកំពុងតែអង្គុយផឹកស្រាជាមួយមិត្តភ័ក្តិនៅខាងមុខផ្ទះ ម្តាយក្មេកបានងាកមកនិយាយទៅកាន់ជាតាថា៖

**"នេះហើយបានជាប្ដីឯងមិនដែលនៅផ្ទះ មកពីឯងមិនចេះធ្វើឱ្យវាសប្បាយចិត្ត។ ឯងជាប្រពន្ធ គួរតែចេះឃាត់ប្ដី មិនមែនឱ្យវាទៅដើរលេងខាងក្រៅរហូតអ៊ីចឹងទេ"។**

ពាក្យសម្ដីទាំងនោះបានធ្វើឱ្យជាតាមានអារម្មណ៍ដូចជាត្រូវគេចាក់ដោយកាំបិត នាងបានព្យាយាមទប់ទឹកភ្នែកមិនឱ្យហូរនៅចំពោះមុខពួកគេ។

នៅពេលដែលរតនាគេងលក់ទៅហើយ ជាតាបានអង្គុយយំម្នាក់ឯងនៅក្នុងបន្ទប់ នាងមានអារម្មណ៍ថាអស់សង្ឃឹមជាទីបំផុត។ តើនាងត្រូវទ្រាំដល់ពេលណាទៀត? តើនាងត្រូវបន្តរស់នៅក្នុងភាពឈឺចាប់នេះយូរប៉ុណ្ណាទៀត? រាល់ការព្យាយាមរបស់នាងហាក់ដូចជាគ្មានន័យ។ នាងមានអារម្មណ៍ថាខ្លួនឯងដូចជាកំពុងតែលង់ទឹកដែលគ្មាននរណាអាចជួយនាងបានឡើយ កែវភ្នែករបស់នាងក្រហមងាំងព្រោះយំច្រើនពេក នាងបានសម្លឹងមើលទៅខ្លួនឯងក្នុងកញ្ចក់ ឃើញរូបភាពនារីម្នាក់ដែលមានទឹកមុខស្លេកស្លាំង ភ្នែកស្លក់ និងបាត់បង់នូវភាពរស់រវើកទាំងអស់ នាងមានអារម្មណ៍ថាខ្លួនឯងកំពុងតែឈានដល់ចំណុចមួយដែលការអត់ទ្រាំរបស់នាងជិតអស់ហើយ នាងមិនអាចបន្តរស់នៅបែបនេះបានទៀតឡើយ មិនមែនដើម្បីខ្លួនឯងទេ គឺដើម្បីរតនា គេសមនឹងទទួលបានសុភមង្គលនិងភាពកក់ក្ដៅពេញលេញ គំនិតនៃការដើរចេញពីជីវិតដ៏ឈឺចាប់នេះបានចាប់ផ្ដើមលេចឡើងក្នុងចិត្តនាងកាន់តែច្បាស់ឡើងៗ ទោះបីជាវាពោរពេញទៅដោយភាពភ័យខ្លាចនិងភាពមិនច្បាស់លាស់សម្រាប់អនាគតក៏ដោយ នាង

ដឹងថានាងត្រូវតែរកផ្លូវចេញដើម្បីសង្គ្រោះខ្លួនឯងនិងកូនប្រុសរបស់នាង មុនពេលដែលអ្វីៗទាំងអស់ត្រូវបំផ្លាញអស់ទាំងស្រុង។



# ជីវិតពោរពេញដោយសម្ពាធ
# ប៉ុន្តែម៉ាក់នឹងស៊ូទ្រាំដើម្បីកូនម៉ាក់!

# ផ្លូវបំបែក

មួយខែបានកន្លងផុតទៅយ៉ាងលឿន បន្ទាប់ពីថ្ងៃបុណ្យភ្ជុំបិណ្ឌដ៏ឈឺចាប់នោះ ភាពតានតឹងក្នុងផ្ទះរបស់ជាតាបានកើនឡើងពីមួយកម្រិតទៅមួយកម្រិត។ តារាកាន់តែព្រងើយកន្តើយចំពោះគ្រួសារ គេមិនដែលត្រឡប់មកផ្ទះបីទៅបួនថ្ងៃក្នុងមួយសប្តាហ៍ឯណោះ ដោយមិនបានខ្វល់ពីការបារម្ភរបស់ជាតា ឬវត្តមានរបស់រតនាទាល់តែសោះ។ រាល់ពេលដែលគេត្រឡប់មកវិញ តារាតែងតែមានក្លិនស្រា និងទឹកអប់មនុស្សស្រីដែលមិនមែនជាក្លិនរបស់ជាតា បេះដូងរបស់នាងបានរងរបួសរាប់មិនអស់រហូតដល់លែងមានអារម្មណ៍អ្វីទៀតហើយ។

ទឹកភ្នែកក៏ចាប់ផ្តើមរីងស្ងួតបន្តិចម្តងៗ ជំនួសមកវិញដោយភាពសាំនិងទង្វើរបស់តារា។

រតនាកាន់តែកត់សម្គាល់ពីភាពមិនអើពើរបស់ឪពុកគេ ក្មេងតូចនោះលែងសួររកប៉ាទៀតហើយ តែពេលខ្លះគាត់បែរជាសម្លឹងមើលទៅទ្វារដោយទឹកមុខស្រងូតស្រងាត់ដោយមិននិយាយអ្វីមួយម៉ាត់។ ជាតាដឹងថាកូនប្រុសរបស់នាងកំពុងតែឈឺចាប់ ប៉ុន្តែនាងមិនដឹងថាត្រូវធ្វើយ៉ាងណាដើម្បីបិទបាំងភាពពិតដ៏ជូរចត់នេះពីកូនប្រុសរបស់នាងទៀតឡើយ។

ថ្ងៃមួយ ជាតាបានត្រឡប់មកពីធ្វើការវិញនៅពេលល្ងាច ពេលនាងបើកទ្វារចូលផ្ទះ នាងបានឃើញស្បែកជើងមនុស្សស្រីមួយគូនៅខាងមុខផ្ទះ បេះដូងរបស់នាងចាប់ផ្តើមលោតញាប់ខុសពីធម្មតា។ នាងដើរចូលទៅក្នុងផ្ទះយឺតៗ ហើយបានលឺសំឡេងសើចក្អាកក្អាយចេញពីបន្ទប់ទទួលភ្ញៀវ នាងបានឈានជើងចូល

ទៅក្នុងបន្ទប់នោះទាំងអារម្មណ៍ភ័យខ្លាចលាយឡំនឹងការឈឺចាប់ អ្វីដែលនាងបានឃើញនៅពេលនោះបានធ្វើឱ្យពិភពលោករបស់នាងរលំរលាយក្នុងមួយរំពេច។ តារាកំពុងតែអង្គុយលើសាឡុងអោបដៃមនុស្សស្រីម្នាក់យ៉ាងស្និទ្ធស្នាល ហើយពួកគេកំពុងតែសើចសប្បាយជាមួយគ្នា រតនាដែលកំពុងលេងនៅក្បែរនោះបានសម្លឹងមើលទិដ្ឋភាពនោះដោយទឹកមុខធ្ងល់ លាយឡំនឹងភាពភ័យខ្លាច។

តារាបានងាកមកឃើញជាតាឈរទ្រឹងនៅមាត់ទ្វារ ទឹកមុខរបស់គាត់ប្រែប្រួលពីភាពរីករាយទៅជាការភ្ញាក់ផ្អើលនិងបន្ទាប់មកជាការខឹងសម្បារ៖

**"នាងឯងមកដល់តាំងពីពេលណា?"**

គាត់និយាយទាំងសំឡេងខ្លាំងៗ មនុស្សស្រីដែលនៅក្បែរគាត់ក៏ងាកមកមើលជាតាដោយទឹកមុខមិនពេញចិត្តដែរ។

ជាតាមិនអាចនិយាយអ្វីបានឡើយ ទឹកភ្នែករបស់នាងបានហូរចុះមកដោយមិនដឹងខ្លួន នាងមានអារម្មណ៍ថាបេះដូងរបស់នាងត្រូវបានគេកាត់ជាដុំៗ។ នេះជាការឈឺចាប់ដ៏ធំធេងបំផុតដែលនាងមិនធ្លាប់ជួបប្រទះពីមុនមក នាងបានព្យាយាមអត់ទ្រាំអស់ជាច្រើនឆ្នាំ ប៉ុន្តែពេលនេះនាងដឹងថាការអត់ទ្រាំរបស់មនុស្សគឺមានកម្រិត៖

**"នាងគិតថានាងជានរណាបានជានាងមកដល់ផ្ទះបងបែបនេះ?"**

នារីម្នាក់នោះបាននិយាយដោយសំឡេងក្រអឺតក្រទម។

ជាតាមិនបានឆ្លើយអ្វីឡើយ នាងគ្រាន់តែសម្លឹងទៅតារាទាំងទឹកភ្នែកហូរស្រក់។ តារាបានក្រោកឈរហើយដើរមកជិតជាតា៖

**"នាងចង់បានអីទៀត? ខ្ញុំធុញនឹងនាងណាស់ហើយ! ខ្ញុំមិនស្រលាញ់នាងទៀតទេ!"**

គាត់និយាយទាំងសំឡេងខ្លាំងៗដែលធ្វើឱ្យរតនាយំដោយភ័យខ្លាច រតនាបានរត់ទៅអោបជើងជាតាយ៉ាងណែន។

ពាក្យសំដីរបស់តារាបានចាក់ទម្លុះបេះដូងជាតាយ៉ាងខ្លាំង អស់រយៈពេលប្រាំពីរឆ្នាំនៃការលះបង់ អស់រយៈពេលជាច្រើនឆ្នាំនៃការអត់ទ្រាំ ពេលនេះគាត់បាននិយាយពាក្យនេះចេញមកដោយគ្មានការស្តាយក្រោយ។ នាងធ្លាប់គិតថានាងពិតជាគ្មាននរណាក្រៅពីគាត់ឡើយ ប៉ុន្តែពេលនេះ នាងដឹងថានាងមានកូនប្រុសរបស់នាង នាងមានកម្លាំងចិត្តងើបឡើងតស៊ូដើម្បីកូន។

**"ខ្ញុំមិនចង់ឱ្យរតនាធំឡើងឃើញឪពុកម្តាយរបស់គេរស់នៅក្នុងភាពឈឺចាប់និងការមិនយល់ចិត្តគ្នាបែបនេះឡើយ។ ខ្ញុំនឹងនាំរតនាចេញពីទីនេះ។"**

ជាតានិយាយទាំងសំឡេងញ័រៗ ប៉ុន្តែម៉ឺងម៉ាត់។ តារាបានសើចចំអក៖

**"នាងគិតថានាងអាចទៅណាបាន? នាងគ្មានអ្វីក្រៅពីខ្ញុំទេ! នាងគ្មានលុយគ្មានផ្ទះ គ្មាននរណាជួយនាងទេ!"**

**"ខ្ញុំនឹងយកកូនទៅរស់នៅជាមួយខ្ញុំ ខ្ញុំនឹងចិញ្ចឹមគេដោយខ្លួនឯង។ ខ្ញុំមិនត្រូវការអ្វីពីលោកទៀតទេ។"**

ជាតាឆ្លើយទាំងសំឡេងដាច់ដោយដាច់ម៉ាត់ ហាក់ដូចជាសំឡេងដែលចេញមកពីជម្រៅបេះដូងដែលកប់ជ្រៅក្នុងបេះដូង នាងបានអោបរតនាជាប់នឹងខ្លួនយ៉ាងណែន ហើយដើរចេញពីបន្ទប់នោះទាំងមិនងាកក្រោយ។

នៅយប់នោះ ជាតាគេងមិនលក់សោះឡើយ នាងបានគិតពិចារណាយ៉ាងហ្មត់ចត់ពីការសម្រេចចិត្តរបស់នាង។ វាជាការសម្រេចចិត្តដ៏ឈឺចាប់និងគួរឱ្យភ័យខ្លាចបំផុតក្នុងជីវិតរបស់នាង នាងដឹងថាការចាកចេញពីតារាមានន័យថានាងត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើន រួមទាំងការរិះគន់ពីសង្គម ភាពលំបាកផ្នែកហិរញ្ញវត្ថុ និងការចិញ្ចឹមកូនតែម្នាក់ឯង។ ប៉ុន្តែនាងក៏ដឹងថាការបន្តនៅក្នុងអាពាហ៍ពិពាហ៍ដែលពោរពេញដោយភាពឈឺចាប់និងគ្មានក្តីស្រលាញ់នេះរឹតតែបំផ្លាញរូបកាយនិងវិញ្ញាណរបស់នាងថែមទៀត។ អ្វីដែលសំខាន់បំផុតនោះគឺរតនា កូនប្រុសរបស់នាងមិនសមនឹងរស់នៅក្នុងបរិយាកាសពោរពេញដោយការស្អប់ខ្ពើមនិងការមិនយល់ចិត្តគ្នាបែបនេះឡើយ។

ជាតាបានចាប់ផ្តើមរៀបចំផែនការដោយសម្ងាត់ នាងបានរកឯកសារសំខាន់ៗមួយចំនួន រួមមានអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើតកូន និងឯកសារមួយចំនួនទៀត។ នាងបានទូរស័ព្ទទៅម្តាយរបស់នាងដើម្បីរៀបរាប់ពីបញ្ហារបស់នាង ម្តាយរបស់នាងដែលធ្លាប់តែព្រួយបារម្ភពីកូនស្រីរបស់ខ្លួនយូរមកហើយ បានស្វាគមន៍ការសម្រេចចិត្តរបស់ជាតាហើយសន្យាថាជួយនាងគ្រប់បែបយ៉ាង៖

**"កូនអើយ ម៉ាក់យល់ពីកូន។ មកផ្ទះយើងវិញចុះ។ ម៉ាក់នឹងនៅក្បែរកូនជានិច្ច"**

សំឡេងម្តាយរបស់នាងបានធ្វើឱ្យជាតាមានកម្លាំងចិត្តឡើងវិញ។

ពីរថ្ងៃក្រោយមក ជាតាបានទៅជួបមេធាវីម្នាក់ដើម្បីសួរយោបល់អំពីនីតិវិធីលែងលះនិងការប្តឹងសុំសិទ្ធិថែរក្សាកូន មេធាវីបានពន្យល់នីតិវិធីឱ្យនាងស្តាប់យ៉ាងលម្អិត វាមិនមែនជារឿងងាយស្រួលនោះទេ ប៉ុន្តែជាតាបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមមុខនឹងអ្វីៗទាំងអស់។

នៅព្រឹកថ្ងៃមួយដ៏ស្ងប់ស្ងាត់ ជាតាបានដាស់រតនាតាំងពីព្រលឹម នាងបានឱបកូនប្រុសរបស់នាងយ៉ាងណែនហើយនិយាយថា៖

**"រតនាកូនសម្លាញ់! ថ្ងៃនេះយើងនឹងទៅរស់នៅកន្លែងថ្មីជាមួយគ្នាហើយ។ យើងនឹងមានសុភមង្គលវិញហើយ"។**

រតនាបានសម្លឹងមើលទៅម្តាយរបស់គេទាំងភ្នែកព្រឹមៗ ទោះជាគេមិនទាន់យល់ច្បាស់ពីអ្វីដែលកំពុងកើតឡើងក៏ដោយ ក៏គេមានអារម្មណ៍ថាម្តាយរបស់គេកំពុងតែព្យាយាមធ្វើអ្វីមួយដើម្បីពួកគេដែរ។

ជាតាបានរៀបចំឥវ៉ាន់មួយចំនួនដែលចាំបាច់សម្រាប់នាងនិងរតនា។ នាងបានទុករបស់របរជាច្រើននៅក្នុងផ្ទះនោះដែលធ្លាប់ជាផ្ទះរបស់នាង នាងបានក្រឡេកមើលទៅផ្ទះដែលធ្លាប់តែជាកន្លែងផ្តល់ក្តីស្រលាញ់និងក្តីសុខ ប៉ុន្តែឥឡូវ

នេះវាបានក្លាយទៅជាកន្លែងដែលពោរពេញទៅដោយការឈឺចាប់និងអនុស្សាវរីយ៍មិនល្អ។ នាងដឹងថាការចាកចេញនេះនឹងឈឺចាប់ ប៉ុន្តែនាងក៏ដឹងថានេះជាការចាប់ផ្តើមនៃជីវិតថ្មីមួយដែលគ្មានភាពឈឺចាប់ទៀតឡើយ នាងបានកាន់ដៃរតនាយ៉ាងណែន ហើយបានដើរចេញពីផ្ទះនោះទាំងមិនងាកក្រោយ។ ទឹកភ្នែកមួយតំណក់ចុងក្រោយបានហូរចុះមកលើថ្ពាល់របស់នាង បន្ទាប់មកនាងក៏ជូតវាចេញ ហើយសម្លឹងទៅមុខដោយកែវភ្នែកដែលពោរពេញទៅដោយការសម្រេចចិត្តយ៉ាងមុតមាំ នេះជាផ្លូវបំបែករបស់នាង ផ្លូវដែលនាងត្រូវជ្រើសរើសដើម្បីខ្លួនឯងនិងកូនប្រុសរបស់នាង។



## ជីវិតមួយនេះ ដើរដល់ចំណុចនេះ!

## ម៉ាក់មិនចង់ទេកូន។

# ការចាប់ផ្តើមជីវិតថ្មី

ជាតាបានកាន់ដៃរតនាយ៉ាងណែន ខណៈរថយន្តតាក់ស៊ីបានបើកបរឆ្ងាយចេញពីផ្ទះដ៏ធំនោះ។ ផ្ទះដែលធ្លាប់តែជាកន្លែងផ្តល់ក្តីស្រលាញ់និងសុភមង្គល ប៉ុន្តែពេលនេះ វាបានក្លាយទៅជារឿងឈឺចាប់ បែកបាក់ព្រាត់ប្រាស់គ្នាទៅវិញ។ ទឹកភ្នែកចុងក្រោយដែលបានស្រក់ចុះមកលើថ្ពាល់របស់នាងបានរីងស្ងួតបាត់ទៅហើយ ជំនួសមកវិញដោយកម្លាំងចិត្តថ្មីមួយដែលបានផុសចេញពីជម្រៅបេះដូងរបស់នាង។ នាងសម្លឹងទៅកូនប្រុសរបស់នាងដែលកំពុងតែងើបមុខមើលទៅក្រៅបង្អួចដោយកែវភ្នែកឆ្ងល់៖

**"ម៉ាក់! យើងទៅណា?"** រតនាសួរទាំងសំឡេង ងុលៗ។

ជាតាបានឱបកូនប្រុសរបស់នាងយ៉ាងណែន ហើយនិយាយថា៖

**"យើងទៅផ្ទះជីដូនជីតាកូនឯង យើងនឹងមានសុភមង្គលនៅទីនោះ"។**

ពួកគេបានទៅដល់ផ្ទះរបស់ឪពុកម្តាយជាតានៅឯជាយក្រុង ដែលមានផ្ទះឈើតូចមួយ ប៉ុន្តែពោរពេញទៅដោយភាពកក់ក្តៅនិងក្តីស្រលាញ់។ ម្តាយរបស់ជាតាបានរត់មកឱបនាងទាំងទឹកភ្នែករលីងរលោង ៖

**"កូនអើយ! ម៉ាក់ដឹងថាកូនពិបាកណាស់"។**

ឪពុករបស់នាងបានទះស្មានាងតិចៗ ហើយនិយាយថា ៖

**"កូនបានសម្រេចចិត្តត្រូវហើយ។ យើងនឹងនៅក្បែរកូនជានិច្ច"។**

ការស្វាគមន៍ដ៏កក់ក្តៅនេះបានធ្វើឱ្យដាតាមានអារម្មណ៍ថាខ្លួនឯងមានកម្លាំងចិត្តឡើងវិញ បន្ទាប់ពីរងទុក្ខវេទនាអស់ជាច្រើនឆ្នាំ ជីវិតថ្មីរបស់ដាតានិងរតនាបានចាប់ផ្តើមដោយភាពលំបាកបន្តិចបន្តួច។ ដាតានៅតែបន្តការងារជាបុគ្គលិករដ្ឋបាលដដែល ប៉ុន្តែនាងដឹងថាប្រាក់ខែរបស់នាងមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់រតនានិងការចំណាយផ្សេងៗទៀតឡើយ។ នាងបានព្យាយាមរកការងារបន្ថែមដើម្បីបង្កើនប្រាក់ចំណូល រាល់យប់បន្ទាប់ពីរតនាគេងលក់ នាងអង្គុយដេរសម្លៀកបំពាក់លក់តាមអនឡាញ ឬធ្វើនំលក់ឱ្យអ្នកជិតខាង។ ពេលខ្លះនាងក៏ត្រូវធ្វើការរហូតដល់ពាក់កណ្តាលយប់ដែរ ភាពនឿយហត់បានធ្វើឱ្យរូបរាងកាយរបស់នាង បាក់ទ្រុឌទ្រោមប៉ុន្តែនាងមិនដែលត្អូញត្អែរឡើយ ព្រោះរាល់ការនឿយហត់របស់នាងគឺដើម្បីអនាគតកូនប្រុសរបស់នាង។

រតនាក៏ចាប់ផ្តើមសម្របខ្លួនទៅនឹងបរិយាកាសថ្មីដែរ ដំបូងឡើយគេមានអារម្មណ៍ចម្លែកៗមុននឹងអាចសម្របខ្លួនបានបន្តិចម្តងៗ ប៉ុន្តែដោយសារតែមានការយកចិត្តទុកដាក់និងក្តីស្រលាញ់ពេញលេញពីម្តាយនិងជីដូនជីតា រតនាក៏ចាប់ផ្តើមរីករាយនឹងជីវិតថ្មីរបស់គេវិញ។ គេចូលរៀននៅសាលាបឋមសិក្សាថ្មីមួយដែលនៅជិតផ្ទះ ដាតាតែងតែទៅទទួលរតនាពីសាលាដោយផ្ទាល់ដៃរាល់ថ្ងៃដែលធ្វើឱ្យរតនាសប្បាយចិត្តជាខ្លាំង ពេលល្ងាចពួកគេតែងតែធ្វើលំហាត់ជាមួយគ្នា អានសៀវភៅជាមួយគ្នា ហើយលេងហ្គេមជាមួយគ្នា ស្នាមញញឹមបានលេចឡើងលើផ្ទៃមុខរបស់ដាតាវិញបន្តិចម្តងៗ។

ការបែកបាក់គ្នា រវាងជាតានិងតារាចៀសមិនផុតពីមានគេនិយាយដើម ជាពិសេស ពីសំណាក់គ្រួសារខាងតារា។ ពួកគេបានទៅផ្សព្វផ្សាយរឿងមិនល្អអំពីជាតាគ្រប់ទីកន្លែង ដោយនិយាយថានាងជាមនុស្សស្រីមិនល្អ ដែលបោះបង់ប្តីនិងគ្រួសារ។ ម្តាយក្មេករបស់នាងថែមទាំងបានទូរស័ព្ទមកជេរប្រមាថនាងទៀតផងថា៖

**"ឯងជាស្រីកំណាច! ឯងបានបំផ្លាញគ្រួសារកូនខ្ញុំ!"**

ជាតាបានត្រឹមតែស្តាប់ដោយស្ងៀមស្ងាត់ ហើយបិទទូរស័ព្ទ។ នាងលែងខ្វល់ពីពាក្យសម្តីរបស់ពួកគេទៀតហើយ។ នាងដឹងថានាងបានធ្វើអ្វីដែលត្រឹមត្រូវសម្រាប់ខ្លួនឯងនិងកូន។

ដំណើរការលែងលះនិងការប្តឹងសុំសិទ្ធិថែរក្សាកូនបានប្រព្រឹត្តទៅដោយមានការលំបាក តារាបានព្យាយាមរារាំងគ្រប់បែបយ៉ាង ហើយមិនព្រមផ្តល់ការគាំទ្រអ្វីឡើយ។ គាត់បានអះអាងថាជាតាមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមវតនានោះទេ ដូចនេះជាតាត្រូវតែប្រឹងប្រែងបង្ហាញដល់តុលាការថានាងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ជីវិតដ៏ល្អប្រសើរសម្រាប់កូនប្រុសរបស់នាង។ នាងបានដាក់ភស្តុតាងទាំងអស់ រួមទាំងការចំណាយផ្ទាល់ខ្លួនរបស់នាង និងការខិតខំរកប្រាក់បន្ថែម នាងបានបញ្ជាក់យ៉ាងច្បាស់ថាវតនាមានសុភមង្គលនិងភាពកក់ក្តៅពេលនៅជាមួយនាង។

ក្រោយពីការតស៊ូផ្នែកច្បាប់ដ៏លំបាកជាច្រើនខែ ទីបំផុតតុលាការក៏បានសម្រេចផ្តល់សិទ្ធិថែរក្សារតនាទាំងស្រុងទៅឱ្យជាតា។ តុលាការក៏បានបង្គាប់ឱ្យតារាបង់ប្រាក់ឧបត្ថម្ភសម្រាប់រតនាប្រចាំខែដែរ ទោះបីជាចំនួននោះមិនច្រើនប៉ុន្មានក៏ដោយ។ នៅពេលដែលជាតាបានលឺសាលក្រម នាងមិនអាចទប់ទឹកភ្នែករបស់នាងបានឡើយ លើកនេះមិនមែនជាទឹកភ្នែកនៃការឈឺចាប់ទៀតទេ តែជាទឹកភ្នែកនៃក្តីសប្បាយរីករាយនិងធូរទ្រូងជាខ្លាំង នាងមានអារម្មណ៍ថាបន្ទុកដ៏ធ្ងន់ដែលសង្កត់លើស្មារបស់នាងត្រូវបានដកចេញអស់ហើយ។

ជីវិតជាម្តាយមេម៉ាយមិនមែនជារឿងងាយស្រួលនោះទេ មានថ្ងៃខ្លះជាតាមានអារម្មណ៍ថានឿយហត់ខ្លាំងរហូតដល់ចង់បោះបង់ ប៉ុន្តែនៅពេលនាងក្រឡេកមើលទៅរតនា នាងក៏មានកម្លាំងចិត្តឡើងវិញ។ រតនាតែងតែជាកម្លាំងចចិត្តសម្រាប់នាង នាងលែងយំម្នាក់ឯងរាល់យប់ទៀតហើយ ជំនួសមកវិញ នាងបានចំណាយពេលពេលល្ងាចអានសៀវភៅជាមួយរតនា ឬមើលទូរទស្សន៍ជាមួយឪពុកម្តាយរបស់នាង ភាពកក់ក្តៅនៃគ្រួសារតូចរបស់នាងបានជួយព្យាបាលរបួសក្នុងចិត្តរបស់នាងបន្តិចម្តងៗ។

ជាតាបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលខ្លីៗដើម្បីបង្កើនជំនាញការងាររបស់នាង នាងបានក្លាយជាបុគ្គលិកឆ្នើមនៅក្រុមហ៊ុនរបស់នាង។ នាងបានបង្កើតមិត្តភ័ក្តិថ្មីៗដែលយល់ចិត្តនិងផ្តល់ការគាំទ្រដល់នាង រួចនាងក៏បានរកឃើញចំណង់ចំណូលចិត្តថ្មីៗផងដែរ ដូចជាការដាំផ្កានិងការរៀនធ្វើនំផ្អែមប្រភេទថ្មីៗ។ នាងចាប់ផ្តើមសើចនិងស្រស់ស្រាយបានច្រើនជាងមុន ស្នាមញញឹមពិតប្រាកដបានលេចឡើងលើផ្ទៃមុខរបស់នាងវិញ។

នៅពេលដែលនាងមើលទៅកញ្ចក់ នាងបានឃើញរូបភាពនារីម្នាក់ដែលខុសពីពេលមុន។ ភ្នែករបស់នាងនៅតែមានស្នាមដាំបន្តិចបន្តួចដោយសារការយំមកយូរឆ្នាំ ប៉ុន្តែឥឡូវនេះវាបានបញ្ចេញពន្លឺនៃក្តីសង្ឃឹម ភាពរឹងមាំ និងសេរីភាព។ នាងបានរៀនសូត្រថាការស្រលាញ់ខ្លួនឯងនិងកូនគឺជារឿងសំខាន់បំផុត។ ការចាកចេញពីអាពាហ៍ពិពាហ៍ដែលពោរពេញដោយទុក្ខសោកមិនមែនជាការបរាជ័យនោះទេ តែជាការចាប់ផ្តើមថ្មីមួយដើម្បីស្វែងរកសុភមង្គលពិតប្រាកដ។ នាងបានចាប់ផ្តើមមើលឃើញពន្លឺភ្លឺចែងចាំងនៅថ្ងៃខាងមុខ ដែលជាសញ្ញានៃអនាគតដ៏ភ្លឺស្វាងសម្រាប់នាងនិងរតនា។



# ចាកចេញពេលនេះ គឺជាជម្រើសល្អបំផុត!

# ក្តីសង្ឃឹមនិងអនាគត

ប៉ុន្មានឆ្នាំបានកន្លងផុតទៅយ៉ាងលឿនដូចជាខ្យល់ព្យុះ ដាតាបានផ្លាស់ប្តូរទាំងស្រុង ពីនារីដែលពោរពេញទៅដោយការឈឺចាប់និងអស់សង្ឃឹម ទៅជាស្ត្រីម្នាក់ដែលមានភាពរឹងមាំ មានទំនុកចិត្តលើខ្លួនឯង និងពោរពេញទៅដោយក្តីសង្ឃឹម ការសម្រេចចិត្តដើរចេញពីអាពាហ៍ពិពាហ៍ដ៏ជូរចត់នោះ គឺជាចំណុចរបត់ដ៏សំខាន់ក្នុងជីវិតរបស់នាង។

បន្ទាប់ពីតុលាការបានផ្តល់សិទ្ធិថែរក្សារតនាទាំងស្រុងឱ្យនាង ដាតាបានខិតខំប្រឹងប្រែងធ្វើការទាំងថ្ងៃទាំងយប់ នាងបានបង្កើនចំណេះដឹងនិងជំនាញរបស់នាងតាមរយៈការរៀនវគ្គខ្លីៗបន្ថែម។ ភាពឆ្លាតវៃនិងការតស៊ូរបស់នាងបានធ្វើឱ្យនាងទទួលបានការដំឡើងតំណែងជាអ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុនដែលនាងកំពុងធ្វើការ។ ប្រាក់ចំណូលរបស់នាងបានកើនឡើង ដែលធ្វើឱ្យនាងអាចជួលផ្ទះតូចមួយនៅជិតសាលារតនាបាន ទោះជានាងនៅតែត្រូវឪពុកម្តាយផ្គត់ផ្គង់នាងខ្លះៗក៏ដោយ ក៏នាងលែងជាបន្ទុករបស់ពួកគាត់ទៀតហើយ នាងបានក្លាយជាបង្គោលដ៏រឹងមាំសម្រាប់គ្រួសារតូចរបស់នាង។

រតនាក៏រីកចម្រើនធំធាត់ឡើងដោយមានការយកចិត្តទុកដាក់និងក្តីស្រលាញ់យ៉ាងពេញលេញពីម្តាយរបស់គេ រតនាជាក្មេងប្រុសដែលមានភាពវៃឆ្លាត មានសុជីវធម៌ និងតែងតែទទួលបានលទ្ធផលល្អក្នុងការសិក្សា គេចូលចិត្តសកម្មភាពក្រៅផ្ទះ ហើយដាតាតែងតែចំណាយពេលលេងជាមួយគាត់រាល់ពេលដែលនាងទំនេរ។ រតនាតែងតែនិយាយថា ៖

**"ម៉ាក់ជាវីរនារីរបស់ខ្ញុំ!"**

ពាក្យសម្តីដ៏សាមញ្ញរបស់កូនប្រុស បានផ្តល់កម្លាំងចិត្តយ៉ាងខ្លាំងដល់ដាតាភាពរីករាយនិងសុភមង្គលរបស់រតនាក៏ជាសុភមង្គលរបស់ដាតាផងដែរ។

ដាតាបានរកឃើញមិត្តភក្តិថ្មីៗជាច្រើននាក់នៅកន្លែងធ្វើការនិងតាមរយៈសកម្មភាពសង្គមដែលនាងបានចូលរួម។ ពួកគេជាមនុស្សដែលយល់ចិត្តនិងផ្តល់កម្លាំងចិត្តដល់នាង នាងលែងមានអារម្មណ៍ឯកាដូចកាលពីមុនទៀតហើយ នាងក៏បានបន្តចំណង់ចំណូលចិត្តដាំផ្កានិងធ្វើនំផ្អែមរបស់នាងផងដែរ។ សួនផ្កាតូចមួយនៅមុខផ្ទះរបស់នាងបានរីកស្គុសស្គាយដោយផ្កាចម្រុះពណ៌ស្រស់ស្អាត ហើយក្លិននំផ្អែមតែងតែឈ្ងុយឈ្ងប់ពេញផ្ទះ នាងបានរកឃើញភាពសប្បាយរីករាយពីរឿងសាមញ្ញៗក្នុងជីវិត។

ថ្ងៃមួយ ដាតាបានជួបតារាដោយចៃដន្យនៅផ្សារ តារាមើលទៅចាស់ជាងមុនច្រើន ទឹកមុខរបស់គាត់ហាក់ដូចជាពោរពេញទៅដោយភាពនឿយហត់និងភាពសោកសៅ។ គាត់បានសម្លឹងមកដាតាដោយទឹកមុខស្តាយក្រោយ ៖

"ដាតា! ខ្ញុំ... ខ្ញុំសុំទោស..." គាត់និយាយទាំងសំឡេងស្អកៗ។

ដាតាមិនបានឆ្លើយអ្វីឡើយ នាងគ្រាន់តែងក់ក្បាលតិចៗ ហើយញញឹមយ៉ាងស្រាលដោយគ្មានការឈឺចាប់ឬការស្អប់ទៀតឡើយ។ រតនាដែលនៅក្បែរដាតាបានសម្លឹងទៅឪពុករបស់គេដោយទឹកមុខមិនស្គាល់ ដាតាបានចាប់ដៃរតនាហើយដើរហួសទៅដោយមិនងាកក្រោយ នាងបានអភ័យទោសឱ្យគាត់រួចទៅហើយ មិនមែនដើម្បីគាត់ទេគឺដើម្បីខ្លួនឯងនិងដើម្បីអាចបន្តដំណើរទៅមុខបាន។

ជាតាបានយលឃើញថា សុភមង្គលមិនមែនកើតចេញពីអ្នកដទៃនោះទេ ប៉ុន្តែវាកើតចេញពីកម្លាំងចិត្តនិងការតាំងចិត្តរបស់ខ្លួនឯង។ នាងបានយកការឈឺចាប់ទាំងអស់មកធ្វើជាកម្លាំងជំរុញឱ្យនាងកាន់តែរឹងមាំ នាងបានឆ្លងកាត់ព្យុះភ្លៀងក្នុងជីវិតដោយភាពក្លាហាន ហើយទីបំផុតក៏បានរកឃើញពន្លឺថ្មីសម្រាប់ខ្លួនឯងនិងកូនប្រុសរបស់នាង។

យប់មួយ ជាតាបានអង្គុយក្បែរបង្អួចមើលទៅព្រះច័ន្ទពេញវង់ដែលចាំងពន្លឺស្រាលស្រទន់ នាងបានសម្លឹងមើលទៅរូបភាពរបស់នាងក្នុងកញ្ចក់ដែលឆ្លុះបញ្ចាំងពីពន្លឺព្រះច័ន្ទ។ ភ្នែករបស់នាងដែលធ្លាប់តែពោរពេញទៅដោយការឈឺចាប់និងទឹកភ្នែក ឥឡូវនេះបានបញ្ចេញពន្លឺនៃក្តីសង្ឃឹម ភាពស្ងប់ស្ងាត់និងសេចក្តីសុខ។ នាងញញឹម! នាងដឹងថាផ្លូវនៅខាងមុខនៅវែងឆ្ងាយទៀត ប៉ុន្តែនាងត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមមុខនឹងវា នាងមានរតនានៅក្បែរ នាងមានក្តីស្រលាញ់ពីឪពុកម្តាយ នាងមានកម្លាំងជម្រុញពីក្នុងចិត្តនាងផ្ទាល់។

រតនាដែលកំពុងគេងលក់បានងាកខ្លួនបន្តិច ជាតាបានក្រោកទៅដណ្តប់ភួយឱ្យកូនប្រុសរបស់នាង ហើយថើបថ្ងាសគេថ្នមៗ ៖

**"ម៉ាក់ស្រលាញ់កូនណាស់ រតនា"។**

នាងបានត្រឡប់មកអង្គុយក្បែរបង្អួចវិញ ហើយបន្តសម្លឹងទៅព្រះច័ន្ទ កែវភ្នែករបស់នាងបានបញ្ចេញពន្លឺនៃសុភមង្គលដ៏ពិតប្រាកដ ជាពន្លឺដែលឆ្លុះបញ្ចាំងពីជ័យជម្នះនៃស្មារតីរបស់មនុស្សស្រីម្នាក់ដែលបានឆ្លងកាត់រឿងលំបាកគ្រប់យ៉ាង ហើយបានរកឃើញផ្លូវទៅកាន់ពន្លឺនៃក្តីសង្ឃឹមជាថ្មីម្តងទៀត។



# ក្តីសុខគឺកើតចេញពីខ្លួនយើងផ្ទាល់

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោក លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលដ៏មានតម្លៃ អានរឿង "កែវភ្នែកនាង" តាំងពីដើមរហូតដល់ចប់។ រាល់ពាក្យពេចន៍ និងរឿងរ៉ាវដែលបានសរសេរឡើង គឺកើតចេញពីបំណងចង់ចែករំលែកនូវសារមួយអំពីភាពរឹងមាំរបស់មនុស្សស្រី ការតស៊ូក្នុងជីវិត និងពន្លឺនៃក្តីសង្ឃឹម ដែលតែងតែមានជានិច្ច ទោះបីជាត្រូវឆ្លងកាត់ឧបសគ្គដ៏លំបាកយ៉ាងណាក៏ដោយ។

ជាពិសេស ខ្ញុំបាទ សូមអរគុណដល់ប្រភពនៃកម្លាំងចិត្ត និងការបំផុសគំនិតទាំងអស់ ដែលបានធ្វើឱ្យរឿងនេះអាចលេចចេញជារូបរាងឡើង។ សង្ឃឹមថា រឿងនេះនឹងបន្សល់ទុកនូវអារម្មណ៍ល្អ និងសារវិជ្ជមានណាមួយនៅក្នុងចិត្តអ្នកអានគ្រប់ៗរូប។

សូមអរគុណ!


ប្រលោមលោកខ្លី
កែវភ្នែកនាង
ទុក្ខលំបាក
ភាពឯកោ
ការមើលងាយ
ដែលមនុស្សស្រីជាច្រើនលាក់ទុកក្នុងចិត្ត
រក្សាសិទ្ធដោយ៖ Healthy Tips & Freereadkh